**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនូវទីតាំងដីសម្រាប់សាងសង់ រោងចក្រអគ្គិសនី ៤០០ មេហ្គាវ៉ាត់ ជាមួយកំពង់ផែនាវាដឹកប្រេង ឧស្ម័ន និងបរិក្ខារអគ្គិសនី និងស្ថានីយបូមប្រេងនិងឧស្ម័ន ដែលមានទីតាំងស្ថិតនៅក្នុង ភូមិកោះរះក្រោម ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្ដាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/០១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

## សម្រេច

**មាត្រា១ .-**

ត្រូវបានកំណត់ផ្ទៃដីទំហំ ៤៣ (សែសិបបី) ហិកតា សម្រាប់ធ្វើការសាងសង់រោងចក្រអគ្គិសនី ៤០០ មេហ្គាវ៉ាត់ ជាមួយកំពង់ផែនាវាដឹកប្រេង ឧស្ម័ន និងបរិក្ខារអគ្គិសនី និងស្ថានីយបូមប្រេងនិងឧស្ម័ន ដែលមានទីតាំងស្ថិតនៅក្នុងភូមិកោះរះក្រោម ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល។

**មាត្រា២ .-**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដីទំហំ ៤៣ (សែសិបបី) ហិកតា ខាងលើនេះ ជាប្រភេទដីដែលមានលក្ខណសម្បត្តិជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រកបដោយបេបគតិយុត្ត ស្របតាមមាត្រា១៥ មាត្រា១៦ មាត្រា១៧ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ និងមាននិយាមកាដូចខាងក្រោម៖

| ចំណុច | និយាមកា (WGS 1984-48N) X | Y |
|---|---|---|
| **១- រោងចក្រអគ្គិសនី** | | |
| A | 508395.0974 | 1275348.3457 |
| B | 508699.0695 | 1275699.8582 |
| C | 508919.0770 | 1275579.6270 |
| D | 509276.9410 | 1275210.0700 |
| E | 509353.8423 | 1275107.5845 |
| F | 509113.8625 | 1274850.1708 |
| **២- ផ្លូវចេញចូល** | | |
| G | 508441.9544 | 1275315.8695 |
| H | 508416.9715 | 1275333.1851 |
| I | 508242.9395 | 1275152.9376 |
| J | 508277.1730 | 1275145.2006 |
| **៣- កំពង់ផែ និងស្ថានីយបូមប្រេងនិងឧស្ម័ន** | | |
| I | 508242.9395 | 1275152.9376 |
| J | 508277.1730 | 1275145.2006 |
| K | 508368.2034 | 1275112.1357 |
| L | 508194.7488 | 1274932.3389 |
| M | 508065.3260 | 1274968.9824 |

**មាត្រា៣ .-**

ត្រូវបានហាមឃាត់នូវរាល់សកម្មភាពទន្ទ្រានកាន់កាប់ ជីកដី ដោះដូរ ទិញលក់ ផ្ទេរកម្មសិទ្ធិឬផ្ទេរសិទ្ធិកាន់កាប់ដី ការចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញលិខិតអនុញ្ញាតឱ្យសាងសង់ថ្មីនៅក្នុងបរិវេណដី ដូចបានកំណត់ក្នុងមាត្រា២ខាងលើ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បម្រើផលប្រយោជន៍សាធារណៈរបស់រដ្ឋ។

រាល់ការបំពានលើបទប្បញ្ញត្តិដូចមានចែងក្នុងកថាខណ្ឌខាងលើ អ្នកប្រព្រឹត្តបទល្មើសត្រូវទទួលទណ្ឌកម្មដូចមានចែងនៅក្នុងច្បាប់ភូមិបាលដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

**មាត្រា៤ .-**

ម្ចាស់កម្មសិទ្ធិឬភោគីនៃដីស្ថិតក្នុងបរិវេណដីដូចមានកំណត់ក្នុងមាត្រា២ នៃអនុក្រឹត្យនេះត្រូវផ្ទេរកម្មសិទ្ធិជូនរដ្ឋ ដើម្បីជាប្រយោជន៍សាធារណៈ ដោយទទួលបាននូវការទូទាត់សំណងពីគណៈកម្មការដោះស្រាយផលប៉ះពាល់គម្រោងសាងសង់រោងចក្រអគ្គិសនី ៤០០ មេហ្គាវ៉ាត់ ជាមួយកំពង់ផែនាវាដឹកប្រេង ឧស្ម័ន និងបរិក្ខារអគ្គិសនី និងស្ថានីយបូមប្រេងនិងឧស្ម័ន ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។

**មាត្រា៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អគ្គនាយកអគ្គិសនីកម្ពុជា និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

២

**ផែនទីទីតាំងរោងចក្រផលិតអគ្គិសនី អានុភាព ៤០០ មេហ្គាវ៉ាត់**

**ជាឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃព្រហ. ១០កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៩**




| ចំនុច | និយាមកា (WGS1984-48N) | |
|---|---|---|
| | X | Y |
| 1- រោងចក្រអគ្គិសនី | | |
| A | 508395.0974 | 1275348.3457 |
| B | 508699.0695 | 1275699.8582 |
| C | 508919.0770 | 1275579.6270 |
| D | 509276.9410 | 1275210.0700 |
| E | 509353.8423 | 1275107.5845 |
| F | 509113.8625 | 1274850.1708 |
| | | |
| 2- ផ្លូវចេញចូល | | |
| G | 508441.9544 | 1275315.8695 |
| H | 508416.9715 | 1275333.1851 |
| I | 508242.9395 | 1275152.9376 |
| J | 508277.1730 | 1275145.2006 |
| | | |
| 3- ផែ | | |
| I | 508242.9395 | 1275152.9376 |
| J | 508277.1730 | 1275145.2006 |
| K | 508368.2034 | 1275112.1357 |
| L | 508194.7488 | 1274932.3389 |
| M | 508065.3260 | 1274968.9824 |
| | | |